ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១១៨២
ចុះថ្ងៃ១០ ខែតុលា ឆ្នាំ២០១៩
សាលក្រមលេខៈ ២២១/២៣ (ឃ)
ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះសីហនុ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ វេលាម៉ោងប្រាំបី និងសាមសិបនាទី ព្រឹក នៅសាលាដំបូងខេត្តព្រះសីហនុ ដោយមានសមាសភាពជំនុំជម្រះដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ១១៨២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ដែលមានៈ

១.ជនជាប់ចោទឈ្មោះ [redacted] SHI XIAN ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិចិន មុខរបរទេសចរណ៍ ទីកន្លែងកំណើតនៅ [redacted] ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួនមិនពិតប្រាកដ ប្រពន្ធឈ្មោះ [redacted] LING (រ) មានកូនចំនួន ០២ នាក់ ឪពុកឈ្មោះ [redacted] ZHONG LI (រស់) ម្តាយឈ្មោះ [redacted] YING (រស់) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន "គ្មាន"។

-ឃាត់ខ្លួនថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ៤៩៤៨ ត.ព.ជ/១៩ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

២.ជនជាប់ចោទឈ្មោះ [redacted] XIAO DONG ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិចិន មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួនមិនពិតប្រាកដ នៅ លីវ ឪពុកឈ្មោះ [redacted] ZENG MING (រស់) ម្តាយឈ្មោះ [redacted] XIU HIU (រស់) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន "គ្មាន"។

-ឃាត់ខ្លួនថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ៤៩៥០ ត.ព.ជ/១៩ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

-មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ជាប់ចោទពីបទៈ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** ប្រព្រឹត្តនៅ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **២៥៣** នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] QIANG ភេទប្រុស អាយុ២៩ ឆ្នាំ ជនជាតិចិន មានទីលំនៅបច្ចុប្បន្ននៅ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

-បានឃើញរបាយការណ៍លេខៈ **១៣៣៤ រ.ប.ក/១៩** ចុះថ្ងៃទី១០ តុលា ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។

-បានកំណត់ហេតុទទួលវត្ថុតាងលេខៈ **៥៣៣ វ.ត/១៩** ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់លេខាធិការដ្ឋានសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ**៥៤៥៨ អ.យ.គ/១៩** ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ **១៦៨ អ.យ.ត/១៩** ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីកាសម្រេចបញ្ជូនរឿងសំណុំរឿងទៅជំនុំជម្រះលេខៈ **១៣៩ ត.ព.រ/២០** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្នលេខៈ **លេខៈ២២៥ ត.ព.ដ/២០ លើឈ្មោះ** [redacted] SHI XIAN និងលេខៈ **២២៦ ត.ព.ដ/២០ លើឈ្មោះ** [redacted] XIAO DONG ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុនៃបណ្ដឹងចោទប្រកាន់មានដូចតទៅ

កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង ៣០ នាទី កម្លាំងជំនាញផែននគរបាលព្រហ្មទណ្ឌបានទទួលព័ត៌មានពីជនជាតិចិនម្នាក់ថា មិត្តភក្ដិរបស់គេម្នាក់ត្រូវបានជនជាតិចិន ចាប់យកទៅបង្ខាំងទុកនៅសណ្ឋាគារមួយកន្លែង ស្ថិតនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ បន្ទាប់ពីសមត្ថកិច្ចទទួលបានព័ត៌មានភ្លាម កម្លាំងជំនាញបានសហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់លេខ២ ចុះទៅធ្វើការត្រួតពិនិត្យ និងឆែកឆេរក្នុងចំណុចទីតាំងសណ្ឋាគារខាងលើ។ ក្នុងប្រតិបត្តិការនោះ កម្លាំងសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនបានជនសង្ស័យចំនួន ០២ នាក់ មានឈ្មោះ [redacted] SHI XIAN ភេទប្រុស អាយុ៣៦ ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] XIAO DONG ភេទប្រុស អាយុ២៩ ឆ្នាំ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខEG9385392 យកទៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីសាកសួរ។ កម្លាំងជំនាញបានធ្វើការដកហូតវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសមាន ទូរស័ព្ទចំនួន០៣ គ្រឿង។ ក្រោយសាកសួរឃើញថា ករណីនេះកើតឡើងដោយសារតែជនរងគ្រោះបានខ្ចីប្រាក់ពីក្រុមរបស់ជនសង្ស័យ ដើម្បីយកទៅលេងល្បែង ហើយនៅពេលជនរងគ្រោះលេងល្បែងចាញ់អស់ប្រាក់ និងគ្មានប្រាក់សងពួកគេវិញ ក៏ត្រូវក្រុមជនសង្ស័យធ្វើការចាប់បង្ខាំងទុក ដើម្បីឱ្យជនរងគ្រោះទាក់ទងទៅក្រុមគ្រួសារធ្វើការដោះស្រាយសងប្រាក់ទៅពួកគេវិញ ទើបពួកគេដោះលែងជនរងគ្រោះឱ្យមានសេរីភាពវិញ។ ក្រោយពីការសាកសួររួច កម្លាំងសមត្ថកិច្ចជំនាញការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុបានកសាងសំណុំរឿងបញ្ជូន



Scanned with CamScanner

ជនសង្ស័យ រួមទាំងវត្ថុតាងមកកាន់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុដើម្បីបន្តចាត់ការតាមនីតិវិធី។

## <u>នាពេលសវនាការ</u>

-ដូចមានក្នុងកំណត់ហេតុស្តីពីការជំនុំជម្រះ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ។

**-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ**

**-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

**-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ**

**-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ**

**-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ**

**-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា**

**-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។**

## សាលាដំបូងខេត្តព្រះសីហនុ

## យល់ឃើញថា

១.ជនជាប់ចោទឈ្មោះ [redacted] SHI XIAN ភេទប្រុស អាយុ៣៦ ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] XIAO DONG ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិចិន (សាវតារជាតិខាងលើ) ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** តាមដីកាសន្និដ្ឋានស្ថាពរលេខ: **១៦៨ អ.យ.ត/១៩** ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ និងត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ បញ្ជូនមកជំនុំជម្រះតាមដីកាសម្រេចបញ្ជូនរឿងមកជំនុំជម្រះលេខ:**១៣៩ ត.ព.ស/២០** ចុះថ្ងៃទ១៤ ខែមករា ឆ្នាំ២០២០។

## ភស្តុតាងមាន:

២.តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] QIANG បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ២៣ និង ០០ នាទី ខ្លួនបានទៅលេងល្បែងនៅកាស៊ីណូទីងសឹង ស្រាប់តែជួបក្រុមចងការប្រាក់ បានមកសួរខ្លួនថា ត្រូវការលុយលេងល្បែងឬអត់? គេឱ្យខ្ចី ពេលនោះខ្លួនក៏បានយល់ព្រមខ្ចី បន្ទាប់មកគេបានយកកាក់កាស៊ីណូចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក មកឱ្យខ្លួនលេងល្បែង ពេលខ្លួនកំពុងលេងក៏មានបក្ខពួកគេចំនួន ០៤ នាក់ នៅចាំដកទឹកពីខ្លួន ១០ % នៅពេលខ្លួនលេងឈ្នះ។ ខ្លួនលេងរហូតដល់ម៉ោង ០០ និង ២០ នាទី ឈានចូលថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ក៏ចាញ់អស់ បន្ទាប់មកក្រុមចងការប្រាក់ចំនួន០៤ នាក់ បានចាប់ខ្លួនចូលក្នុងរថយន្ត (ម៉ាក LEXUS មិនចាំពណ៌ មិនចាំផ្លាកលេខ) រួចដឹកខ្លួនទៅបង្ខាំងទុកនៅសណ្ឋាគារមួយកន្លែង (មិនចាំបន្ទប់) ពេលដល់បន្ទប់ពួកគេបានដាក់ខ្នោះដៃខ្លួននៅក្នុងបន្ទប់ទឹក រួចបានយកពិលឆក់ខ្លួន ហើយបង្ខំខ្លួនឱ្យទាក់ទងទៅក្រុមគ្រួសារ ដើម្បីផ្ញើប្រាក់មកសងពួកគេ ខ្លួនបានទាក់ទងទៅប្រពន្ធខ្លួន ហើយនៅវេលាម៉ោង ១៥ និង ០០ នាទី ថ្ងៃខែឆ្នាំដដែល ប្រពន្ធខ្លួនបានផ្ញើប្រាក់ ចំនួន ៣០.០០០ (បីម៉ឺន) យ័ន្ត មកឱ្យពួកគេ តែពួកគេនៅតែមិន

ព្រមដោះលែងខ្លួន។ រហូតដល់ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង ៣០ នាទី ក៏មានសមត្ថកិច្ចមកដល់ ហើយបានជួយរំដោះខ្លួន និងធ្វើការឃាត់ខ្លួនបក្ខពួកក្រុមនោះបានចំនួន០២ នាក់មកស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុតែម្តង។

៣.ជនជាប់ចោទឈ្មោះ [redacted] SHI XIAN បានឆ្លើយគ្រប់ដំណាក់កាលនីតិវិធីថា: សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ពីព្រោះនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ពេលយប់ ខ្លួន និងជនរងគ្រោះបានដើរលេងល្បែងអស់លុយ រួចជនរងគ្រោះបានខ្ចីលុយពីឈ្មោះ [redacted] XIAO DONG ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក និងបានយកទៅលេងល្បែងចាញ់អស់ទៀត បន្ទាប់មកជនរងគ្រោះក៏បានសុំបន្ទប់របស់ខ្លួនដើម្បីសម្រាក (សម្រាកតាំងពីម៉ោង ៤ ទៀបភ្លឺ រហូតដល់ម៉ោងប្រហែល ០១ រសៀល) ស្រាប់តែមានមិត្តភក្តិរបស់ជនរងគ្រោះបានទូរស័ព្ទមកជនរងគ្រោះដើម្បីឱ្យចុះពីបន្ទប់មកយកលុយដើម្បីសងឈ្មោះ [redacted] XIAO DONG វិញ ក្រោយមកខ្លួន និងឈ្មោះ [redacted] XIAO DONG បានចុះមកខាងក្រោមជាមួយជនរងគ្រោះដើម្បីយកលុយ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង។ ខ្លួនមិនបានចាប់បង្ខាំង និងមិនបានធ្វើទារុណកម្មលើជនរងគ្រោះទេ ព្រមទាំងមិនបានស៊ីឈ្នួលយាមមនុស្សអ្វីដែរ។ ចម្លើយបដិសេធរបស់ជនជាប់ចោទពុំមានភស្តុតាងបញ្ជាក់ឱ្យបានច្បាស់លាស់នោះឡើយ។

៤.ជនជាប់ចោទឈ្មោះ [redacted] XIAO DONG បានឆ្លើយគ្រប់ដំណាក់កាលនីតិវិធីថា: សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩។ ខ្លួនស្គាល់ជនរងគ្រោះឈ្មោះ [redacted] QIANG នៅក្នុងកាស៊ីណូ ហើយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង១៥ និង ០០ នាទី រំលងអធ្រាតឈានចូលថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ជនរងគ្រោះបានខ្ចីលុយខ្លួនចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ដោយបានសន្យាថាព្រឹកស្អែកគេសងខ្លួនវិញ បន្ទាប់មកជនរងគ្រោះបានលេងល្បែងចាញ់អស់ ហើយជនរងគ្រោះគ្មានកន្លែងស្នាក់នៅទើបខ្លួននាំជនរងគ្រោះមកស្នាក់នៅជាមួយខ្លួននៅសណ្ឋាគារ ហៃថាន ដីជា ជាមួយឈ្មោះ [redacted] SHIXIAN។ នៅពេលទៅដល់សណ្ឋាគារជនរងគ្រោះបាននិយាយទូរស័ព្ទ តែមិនដឹងនិយាយទូរស័ព្ទទៅណាទេ បន្ទាប់មកបានប្រាប់ខ្លួនថាស្អែកបានលុយសងខ្លួនហើយ។ លុះស្អែកឡើងជនរងគ្រោះបានប្រាប់ខ្លួនថា មានគេយកលុយមកឱ្យទើបខ្លួន, ឈ្មោះ [redacted] SHIXIAN និងជនរងគ្រោះបានចុះពីសណ្ឋាគារមកជាន់ក្រោម ក៏ស្រាប់តែមានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនបានចាប់ឃុំឃាំង ធ្វើទារុណកម្មបង្ខំឱ្យជនរងគ្រោះទាក់ទងទៅគ្រួសារ ដើម្បីយកប្រាក់សងខ្លួនឡើយ គឺជនរងគ្រោះទាក់ទងទៅគ្រួសារដោយខ្លួនឯងទេ។ ទង្វើរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះ និងរបាយការណ៍របស់សមត្ថកិច្ច ចម្លើយបដិសេធរបស់ជនជាប់ចោទរូបនេះពុំមានភស្តុតាងដោះបន្ទុកបញ្ជាក់ច្បាស់លាស់នោះឡើយ។

៥.តាមរបាយការណ៍លេខ: **១៣៣៤ រ.ប.ក/១៩** ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុបានសន្និដ្ឋានថា៖ ជនរងគ្រោះឈ្មោះ [redacted] QIANG ភេទប្រុស គឺជាជនរងគ្រោះក្នុងករណី ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ បង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] SHI XIAN ភេទប្រុស និងឈ្មោះ [redacted] XIAO DONG ភេទប្រុស ពិតប្រាកដមែន។



Scanned with CamScanner

៦.ទោះបីជនជាប់ចោទទាំងពីរនាក់បានឆ្លើយបដិសេធចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ថាពុំបានចាប់បង្ខាំងជនរងគ្រោះឈ្មោះ [redacted] QIANG ដើម្បីជំរិតទារប្រាក់ ប៉ុន្តែផ្អែកតាមចម្លើយរបស់ជនរងគ្រោះ ជាពិសេសតាមរបាយការណ៍លេខ:១៣៣៨ រ.ប.ក/១៩ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងភស្តុតាងនានាក្នុងសំណុំរឿងបង្ហាញឲ្យឃើញថា ជនជាប់ចោទទាំង ២ នាក់ខាងលើមានការពាក់ព័ន្ធ និងមានសកម្មភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំង ពីបទ: **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** ប្រព្រឹត្តនៅ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ពិតប្រាកដមែន។

៧.កំណត់ហេតុ និងឯកសារនានា ធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។

៨.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ តាមការពិភាក្សាដេញដោល និងការកត់សម្គាល់របស់មេធាវី ឃើញថា ជនជប់ចោទទាំងពីរនាក់ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តំណាងអយ្យការនៅតែតម្កល់សេចក្តីសន្និដ្ឋានស្ថាពរទុកដដែល និងស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់។

៩.លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា: តាមចម្លើយជនរងគ្រោះឃើញថា មានខ្នោះដៃ និងដំបងឆក់ តែកំណត់ហេតុទទួលវត្ថុតាងមិនមានទេ ហើយពុំមានកំណត់ហេតុស្តីពីការឆែកឆេរនៅក្នុងសំណុំរឿងទៀត ជាហេតុធ្វើឱ្យការចោទប្រកាន់លើកូនក្តីខ្លួនពុំមានភាពស៊ីសង្វាក់ទេ ដោយពុំមានភស្តុតាងមកបញ្ជាក់ឱ្យបានច្បាស់លាស់ឡើយ។

១០.លោក [redacted] **សុធា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារបន្ថែមថា: បន្ទាប់ពីការស្តាប់ចម្លើយ ស្តាប់ការពិភាក្សាដេញដោល និងកំណត់ហេតុទទួលវត្ថុតាងឃើញថា មិនឃើញមានខ្នោះដៃ និងដំបងឆក់នៅក្នុងបន្ទប់នោះទេ វាជាអវត្តមាននៃបទល្មើសដោយខ្វះធាតុផ្សំ។ នៅក្នុងបទល្មើសនេះខ្លួនសំណូមពរឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ព្រោះតាមការពិនិត្យសំណុំរឿងឃើញថា ការប្រមូលភស្តុតាងរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយរបស់ជនរងគ្រោះឃើញថាមិនមានភាពស៊ីសង្វាក់គ្នា មានន័យថាជនរងគ្រោះលើកឡើងថាមានខ្នោះដៃ មានដំបងឆក់ ហើយនៅពេលសវនាការកូនក្តីខ្លួនបានឆ្លើយថានគរបាលបានធ្វើការឆែកឆេរ ប៉ុន្តែមិនឃើញមានខ្នោះដៃ និងដំបងឆក់ទេ ចំណុចនេះគឺធាតុផ្សំសត្យានុម័តគឺគ្មានតែម្តង វត្ថុតាងអវត្តមាន ឃើញថាការចោទប្រកាន់កូនក្តីខ្លួនពីបទល្មើសនេះ គឺគ្មានបទល្មើសតែម្តង ខ្លួននៅតែសុំឱ្យតុលាកាសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] XIAO DONG រួចផុតពីបទចោទដដែល តាមសេចក្តីសន្និដ្ឋានរបស់លោកមេធាវីដែលបានបញ្ជាក់ខាងលើ លោកមេធាវីពុំបានមើលខ្លឹមសារនៃមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌឲ្យបានច្បាស់លាស់ឡើយ។

១១.ការលើកឡើងរបស់លោកមេធាវីទាំងពីររូបឃើញថា បានមើលរំលងអំពីប្រតិបត្តិការចុះបង្ក្រាប និងរំដោះជនរងគ្រោះរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងបទល្មើសជាក់ស្តែង ដែលជនជាប់ចោទឈ្មោះ [redacted] XIAO DONG ក៏បានឆ្លើយសារភាពផងដែរថា ខ្លួនពិតជាបានឱ្យប្រាក់

ទៅជនរងគ្រោះខ្ញុំចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ជាកាក់កាស៊ីណូ ក្រោយពីជនរងគ្រោះលេងល្បែងចាញ់អស់ ខ្លួន និងឈ្មោះ [redacted] SHI XIAN ក៏បាននាំជនរងគ្រោះទៅបន្ទប់សណ្ឋាគារជាមួយ រហូតដល់ម៉ោងប្រហែល ១៣ និង ០០ នាទី ទើបសមត្ថកិច្ចជួយរំដោះជនរងគ្រោះបាន និងឃាត់ខ្លួនជនជាប់ចោទតែម្តង ដូចនេះជនជាប់ចោទនៅតែមានការពាក់ព័ន្ធនឹងបទល្មើសចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ។

១២.ជនជាប់ចោទឈ្មោះ [redacted] SHI XIAN ភេទប្រុស អាយុ៣៦ ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] XIAO DONG ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិចិន ជានីតិជន (គ្មានវិបល្លាសស្មារតី) មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

**១៣.វត្ថុចាប់យកមាន៖**

-ទូរស័ព្ទចំនួន ០៣ គ្រឿង ម៉ាក អាយហ្វូន៦ ម៉ាកអាយហ្វូន៦ ផ្លាស និងម៉ាកOPPO **ដែលជនជាប់ចោទបានប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ត្រូវរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។**

១៤.សំដីចុងក្រោយរបស់ជនជាប់ចោទទាំងពីរនាក់: សុំឱ្យតុលាការជួយសម្រាលទោសឱ្យខ្លួនផង ពីព្រោះខ្លួនទើបតែមកប្រទេសកម្ពុជា មិនដឹងច្បាប់នៅប្រទេសកម្ពុជាទេ។

១៥.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] QIANG ភេទប្រុស ជនជាតិចិន ពុំបានប្តឹងទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្តពីជនជាប់ចោទទាំងពីនាក់ទេ តុលាការពុំគប្បីពិចារណ៍អំពីសំណងនេះឡើយ។

១៦.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] SHI XIAN ភេទប្រុស អាយុ៣៦ ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] XIAO DONG ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិចិន ពីបទ: **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** ប្រព្រឹត្ត ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

១៧.ជនជាប់ចោទទាំងពីរនាក់ជាជនជាតិចិន បានប្រព្រឹត្តបទល្មើសនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដូចនេះតុលាការគប្បីហាមឃាត់ចំពោះការចូល និងស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះជនជាប់ចោទឈ្មោះ [redacted] SHI XIAN និងឈ្មោះ [redacted] XIAO DONG សម្រាប់រយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់ពីជនជាប់ចោទទាំងពីរនាក់បានបញ្ចប់ការអនុវត្តទោសពន្ធនាគារ តាមមាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

**១.ផ្តន្ទាទោសលើជនជាប់ចោទ:**

ក.ឈ្មោះ [redacted] SHI XIAN ភេទប្រុស អាយុ៣៩ ឆ្នាំ ជនជាតិចិន (សាវតាជាតិខាងលើ) **ដាក់ពន្ធនាគារ**កំណត់ **០១** (មួយ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ

ក.ឈ្មោះ [redacted] XIAO DONG ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិចិន (សាវតាជាតិខាងលើ) **ដាក់ពន្ធនាគារ**កំណត់ **០១** (មួយ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ

25

ពីបទៈ **ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់** ប្រព្រឹត្តនៅ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ បទល្មើសដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៥៣** នៃក្រមព្រហ្មទណ្ឌ។

២.ហាមឃាត់ចំពោះការចូល និងស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះជនជាប់ចោទឈ្មោះ [redacted] SHI XIAN និងឈ្មោះ [redacted] XIAO DONG (សាវតារជាតិខាងលើ) សម្រាប់រយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់ពីជនជាប់ចោទទាំងពីរនាក់បានបញ្ចប់ការអនុវត្តទោសពន្ធនាគារ។

**៣.វត្ថុចាប់យកមាន៖**

-ទូរស័ព្ទចំនួន ០៣ គ្រឿង ម៉ាក អាយហ្វូន៦ ម៉ាកអាយហ្វូន៦ ផ្លាស និងម៉ាកOPPO

**ដែលជនជាប់ចោទបានប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ត្រូវរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។**

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] SHI XIAN និងឈ្មោះ [redacted] XIAO DONG និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] QIANG និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ**

[redacted] | [redacted]